**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បញ្ញត្តិករទូរគមនាគមន៍កម្ពុជា**

លេខ :..១៧០៥.....ប.ក.ទ.ក.

# សេចក្តីណែនាំ
## ស្តីពី
## វិធានការទប់ស្កាត់ការចែកចាយ និងលក់ស៊ីមកាតទូរស័ព្ទចល័ត ដោយមិនយកអត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ ផ្ទុយពីសារាចរអន្តរក្រសួងលេខ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២

ដោយពិនិត្យឃើញថា កន្លងមកក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត ភ្នាក់ងារចែកចាយឬលក់បន្តបណ្តាញនិងសេវាទូរស័ព្ទចល័ត និងអតិថិជនឬអ្នកប្រើប្រាស់បណ្តាញឬសេវាទូរស័ព្ទចល័តទាំងអស់ ពុំទាន់បានអនុវត្តឲ្យបានពេញលេញ ស្របតាមខ្លឹមសារនៃសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្ម និងការប្រើប្រាស់សេវាកម្មទូរគមនាគមន៍ នៅឡើយ ។ ជាពិសេស បណ្តាក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ រួមទាំងភ្នាក់ងារចែកចាយឬលក់បន្ត បានធ្វើការចែកចាយ ឬលក់ស៊ីមកាតទូរស័ព្ទចល័តដោយលក្ខណៈប្រកួតប្រជែងគ្នាដើម្បីដណ្តើមអតិថិជនពីគ្នាទៅវិញទៅមក រហូតឈានទៅដល់ការពុំយកអត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកជួលជាវសេវាចល័តទូរស័ព្ទដែលជាប្រជាពលរដ្ឋខ្មែរ ក៏ដូចជាជនបរទេស ដោយមិនបានគិតដល់រាល់ហានិភ័យធ្ងន់ធ្ងរកើតមានចំពោះសន្តិសុខជាតិ និងសុវត្ថិភាពសង្គម ។ ជាក់ស្តែង ឆ្លងតាមការស៊ើបអង្កេត ស្រាវជ្រាវរបស់អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ លើករណីឧក្រិដ្ឋកម្មធំៗមួយចំនួនកន្លងមក ដូចជា អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរគ្រឿងញៀន អំពើជួញដូរមនុស្ស ការគំរាមជំរិតទារប្រាក់ ឧក្រិដ្ឋជនបានប្រើប្រាស់បណ្តាញទូរស័ព្ទចល័តដើម្បីធ្វើសកម្មភាព ដោយការប្រើប្រាស់អត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកដទៃ ឬគ្មានអត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់ជនល្មើសត្រូវបានរក្សាទុកនៅក្នុងទិន្នន័យរបស់ក្រុមហ៊ុនឡើយ។ ប្រការនេះបានបង្កភាពស្មុគ្រស្មាញដល់ការស្រាវជ្រាវរបស់សមត្ថកិច្ច ដើម្បីឈានទៅបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងនោះទាន់ពេលវេលា។

រយៈពេលថ្មីៗកន្លងទៅនេះ និងក្នុងស្មារតីទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ច ដើម្បីជានាកិច្ចប្រតិបត្តិការអនុវត្តន៍ឲ្យមានប្រសិទ្ធភាពខ្ពស់នូវសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ខាងលើ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបើកកិច្ចប្រជុំមួយកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ជាមួយប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ដែលកំពុងដំណើរការនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ បានធ្វើសេចក្តីប្រកាសព័ត៌មានមួយស្តីពីវិធានការទប់ស្កាត់ការចែកចាយឬលក់ស៊ីមកាតទូរស័ព្ទចល័តដោយមិនយកអត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អតិថិជន ផ្ទុយពីសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ និងដើម្បីដាក់ចេញនូវវិធានការអនុវត្តយ៉ាងម៉ឺងម៉ាត់ដូចខាងក្រោម ៖

**១**. ចាប់ពីពេលប្រកាសព័ត៌មាននេះតទៅ (ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥) រាល់ការលក់ ឬចែកចាយ

ស៊ីមកាតរបស់ក្រុមហ៊ុន ឬភ្នាក់ងារចែកចាយបន្តរបស់ក្រុមហ៊ុន ដាច់ខាតត្រូវតែយកអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អតិថិជនឲ្យស្របតាមសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ខាងលើ ។ ក្នុងករណីមិនព្រមអនុវត្តតាម អគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ចាត់វិធានការរដ្ឋបាល ឬតាមច្បាប់ជាធរមាន ចំពោះក្រុមហ៊ុន ឬភ្នាក់ងារចែកចាយបន្តរបស់ក្រុមហ៊ុនណាដែលមិនអនុវត្តតាម ដោយម៉ឺងម៉ាត់បំផុត។

២. ទុករយៈពេល ០៣ ខែ ចាប់ពីថ្ងៃប្រកាសព័ត៌មាន (ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥) ដើម្បីអនុញ្ញាតឲ្យប្រតិបត្តិករធ្វើការកែសម្រួល ឬលុបចោលទៅលើស៊ីមកាតទាំងឡាយណា ដែលក្រុមហ៊ុនបានលក់ ឬចែកចាយដោយគ្មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តិសម្គាល់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ទាំងជាប្រជាពលរដ្ឋខ្មែរ និងជនបរទេស ។ អំឡុងពេលនេះ ប្រតិបត្តិករ ត្រូវជូនដំណឹងដល់អតិថិជនអ្នកប្រើប្រាស់របស់ខ្លួនទាំងប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងប្រើប្រាស់បណ្តាញទូរស័ព្ទចល័តរបស់ខ្លួន ហើយពុំទាន់មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ ឲ្យមកបំពេញបែបបទស្របតាមកាលកំណត់ បើពុំដូច្នោះទេនឹងត្រូវលុបចេញពីបណ្តាញប្រើប្រាស់ជាស្វ័យប្រវត្តិ។

ប៉ុន្តែមកទល់ពេលនេះ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា មិនទាន់មើលឃើញថា ទាំងប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ ទាំងភ្នាក់ងារលក់ឬចែកចាយទាំងអស់ ទាំងអ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តទាំងអស់ អនុវត្តតាមខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មានខាងលើនេះនៅឡើយ ហើយនៅតែបន្តចែកចាយ ឬលក់ស៊ីមកាតទូរស័ព្ទចល័តដោយមិនយកអត្តសញ្ញាណប័ណ្ណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ដដែលជាដដែល ។ កាលកំណត់បរិច្ឆេទក្នុងការកំណត់អនុញ្ញាតបញ្ឈប់ការចែកចាយ ឬលក់ស៊ីមកាតទូរស័ព្ទចល័តដោយមិនយកអត្តសញ្ញាណប័ណ្ណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ គឺគិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ មក។

រីឯការកំណត់អនុញ្ញាតឲ្យប្រតិបត្តិករទាំងអស់ធ្វើការកែសម្រួល ឬលុបចោលទៅលើស៊ីមកាតទូរស័ព្ទចល័តទាំងឡាយណា ដែលក្រុមហ៊ុនបានលក់ឬចែកចាយដោយគ្មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ទាំងជាប្រជាពលរដ្ឋខ្មែរ និងជនបរទេស អំឡុងពេលនេះ គឺជាកាតព្វកិច្ចរបស់បណ្តាប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ត្រូវធ្វើការជូនដំណឹងដល់អតិថិជនអ្នកប្រើប្រាស់របស់ខ្លួនទាំងប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងកាន់កាប់ និងប្រើប្រាស់បណ្តាញទូរស័ព្ទចល័តរបស់ខ្លួន ហើយពុំទាន់មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តិសម្គាល់អត្តសញ្ញាណ ឲ្យមកបំពេញបែបបទតាមកាលកំណត់ បើពុំដូច្នោះទេនឹងត្រូវលុបចេញពីបណ្តាញប្រើប្រាស់ជាស្វ័យប្រវត្តិ គឺគិតចាប់ពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ រហូតត្រឹមថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៥ ។

នៅក្នុងស្មារតីនេះ ដើម្បីជានាកិច្ចសហការអនុវត្តន៍ឲ្យមានប្រសិទ្ធភាពខ្ពស់នូវសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ និងសេចក្តីប្រកាសព័ត៌មានរបស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជានៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា សូមធ្វើការណែនាំ និងធ្វើការរំលឹកម្តងទៀត ដល់បណ្តាប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ ព្រមទាំងភ្នាក់ងារចែកចាយឬលក់បន្តបណ្តាញនិងសេវាទូរស័ព្ទចល័តទាំងអស់ និងអ្នកប្រើប្រាស់បណ្តាញនិងសេវាទូរស័ព្ទចល័តទាំងអស់ ព្រមទាំងអ្នកដែលមានបំណងជួលជាវបណ្តាញនិងសេវាទូរស័ព្ទចល័តទាំងអស់ មេត្តាអនុវត្តដូចតទៅ ៖

**ក) ចំពោះប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ រួមទាំងភ្នាក់ងារចែកចាយទាំងអស់ ៖**

**ក១**. ត្រូវបញ្ឈប់ជាដាច់ខាតនូវរាល់ការចែកចាយ ឬលក់ស៊ីមកាតទូរស័ព្ទដោយមិនយកអត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់អ្នកជួលជាវបណ្តាញនិងសេវាទូរស័ព្ទចល័តគ្រប់ប្រភេទ ទោះក្នុងរូបភាព

ណាក៏ដោយ ស្របតាមខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ពីថ្ងៃចុះហត្ថលេខាលើសេចក្តីណែនាំនេះតទៅជាកំហិត។

**ក២**. ត្រូវធ្វើការកែសម្រួល ឬលុបចោលទៅលើស៊ីមកាតទាំងឡាយណា ដែលក្រុមហ៊ុនបានលក់ ឬចែកចាយដោយគ្មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តិសម្គាល់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ទាំងជាប្រជាពលរដ្ឋខ្មែរ និងជនបរទេស ។ មុននឹងធ្វើការលុបចោលទៅបណ្តាស៊ីមកាតទាំងនោះ ប្រតិបត្តិករឬក្រុមហ៊ុនផ្តល់បណ្តាញនិងសេវាទូរស័ព្ទចល័តទាំងអស់ ត្រូវជូនដំណឹងដល់អតិថិជនអ្នកប្រើប្រាស់របស់ខ្លួនទាំងប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងប្រើប្រាស់បណ្តាញនិងសេវាទូរស័ព្ទចល័តរបស់ខ្លួនដែលពុំទាន់មានអត្តសញ្ញាណប័ណ្ណ ឬឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណ ឲ្យមកបំពេញតាមកាលកំណត់ បើពុំដូច្នោះទេនឹងត្រូវលុបចេញពីបណ្តាញប្រើប្រាស់ជាស្វ័យប្រវត្តិ។ កិច្ចការនេះមិនត្រូវអនុវត្តឲ្យហួសពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ ជាកំហិត ។

**ខ) ចំពោះអតិថិជន ឬអ្នកប្រើប្រាស់ ៖**

**ខ១**. ចំពោះអតិថិជន ឬអ្នកប្រើប្រាស់ដែលកំពុងតែកាន់កាប់ស៊ីមកាតទូរស័ព្ទចល័តដែលមិនបានផ្តល់អត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណរបស់ខ្លួន ត្រូវសហការ ឬធ្វើការទំនាក់ទំនងជាមួយបណ្តាក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទដែលខ្លួនបានជួលជាវកន្លងមក មិនឲ្យលើសថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ ជាកំហិត ។ ក្នុងករណីមិនបានអនុវត្តក្នុងកាលបរិច្ឆេទនេះទេ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា នឹងមិនទទួលខុសត្រូវក្នុងការបាត់បង់សិទ្ធិ ឬការកាត់ផ្តាច់បណ្តាញប្រើប្រាស់ដោយប្រការនេះឡើយ។

**ខ២**. ចំពោះអតិថិជន ឬអ្នកជួលជាវបណ្តាញឬសេវាទូរស័ព្ទចល័តថ្មី ត្រូវផ្តល់អត្តសញ្ញាណ និងឯកសារគតិយុត្តសម្គាល់អត្តសញ្ញាណស្របតាមសារាចរអន្តរក្រសួងលេខ ០០១ សរ.មផ.-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ រួមមាន ៖

- អត្តសញ្ញាណសញ្ជាតិខ្មែរមានសុពលភាព ចំពោះប្រជាពលរដ្ឋទូទៅ
- លិខិតសម្គាល់ខ្លួនចេញដោយក្រសួង ស្ថាប័ន អង្គភាពសាមី មានសុពលភាព ចំពោះមន្ត្រីរាជការ
- សង្ឃដីកាមានសុពលភាព ចំពោះព្រះសង្ឃ
- ដោយឡែកចំពោះអនិតិជន ត្រូវឲ្យឪពុកម្តាយ ឬអាណាព្យាបាល ជាអ្នកជួលជាវឲ្យ
- លិខិតឆ្លងដែន ភ្ជាប់នឹងទិដ្ឋាការស្នាក់នៅ មានសុពលភាព ចំពោះជនបរទេស
- លិខិតទទួលស្គាល់ផ្លូវការរបស់ស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន ដែលមានបំណង់យកប្រើប្រាស់រួម និងកំណត់ឲ្យបានច្បាស់លាស់ពីការទទួលខុសត្រូវរបស់បុគ្គល ចំពោះស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន ។

ចាប់ពីថ្ងៃចុះហត្ថលេខាលើសេចក្តីណែនាំនេះ តទៅជាកំហិត ។

ប្រតិបត្តិករផ្តល់សេវាទូរស័ព្ទទាំងអស់ ភ្នាក់ងារចែកចាយ ឬលក់បន្តទាំងអស់ អ្នកប្រើប្រាស់ទាំងអស់ ត្រូវសហការអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ០៤ ខែវិច្ឆិកា ឆ្នាំ២០១៥

**ប្រធាន**

**ម៉ូង ចរិយា**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  " ដើម្បីជូនជ្រាប "
- បណ្តាប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ